ក្រសួងបរិស្ថាន
រាជរដ្ឋាភិបាលកម្ពុជា

ស្ថានទូតជប៉ុន
ប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មានរួម
## ពិធីចុះហត្ថលេខាលើ
## ភាពជាដៃគូនៃការបញ្ចេញកាបូនតិចរវាងភាគីកម្ពុជា និងភាគីជប៉ុន

នារសៀលថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៤ មានរៀបចំប្រារព្ធពិធីចុះហត្ថលេខាលើឯកសារ "ភាពជាដៃគូនៃការបញ្ចេញកាបូនតិចរវាងភាគីកម្ពុជា និងភាគីជប៉ុន" នៅសណ្ឋាគារកាំបូឌីយ៉ាណា រវាងឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងឯកឧត្តម គូម៉ាម៉ារុ យូជី ឯកអគ្គរាជទូតនៃប្រទេសជប៉ុន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។

ការឡើងកំដៅផែនដី គឺជាបញ្ហាដ៏ធ្ងន់ធ្ងរ ដែលបណ្តាប្រទេសទាំងអស់នៅលើពិភពលោកកំពុងប្រឈមមុខជាមួយ ហើយវិធានការជាច្រើនត្រូវបានស្នើឡើងដើម្បីអនុវត្ត សំដៅកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលជាមូលហេតុនៃបញ្ហានេះ។

នៅក្នុងបរិបទនេះ ព្រះរាជាណាចក្រកម្ពុជា និងជប៉ុន បានសម្រេចចិត្តដើម្បីជំរុញភាពជាដៃគូ នៃការបញ្ចេញកាបូនតិច ក្នុងការឈានទៅសម្រេចគោលដៅនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ និងការសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព។

តាមរយៈភាពជាដៃគូនេះ ប្រទេសកម្ពុជា និងជប៉ុន នឹងសហការគ្នាដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅកម្ពុជា តាមរយៈយន្តការឥណទានកាបូនរួមគ្នា (Joint Crediting Mechanism or JCM) និងដើម្បីរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងជាសកលក្នុងការទប់ស្កាត់ការឡើងកំដៅផែនដី។

**យន្តការឥណទានកាបូនរួមគ្នា (JCM)**

JCM គឺជាយន្តការសម្រាប់ជួយសម្រួលដល់ការផ្សព្វផ្សាយបច្ចេកវិទ្យាបញ្ចេញកាបូនតិចឈានមុខគេ ផលិតផល ប្រព័ន្ធ សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាការអនុវត្តសកម្មភាពកាត់បន្ថយ និងរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយចីរភាពនៃប្រទេសកំពុងអភិវឌ្ឍ។ យន្តការនេះជួយវាយតម្លៃ ដោយត្រឹមត្រូវនូវការកាត់បន្ថយការបញ្ចេញ ឬការស្រូបយកឧស្ម័នផ្ទះកញ្ចក់នៃគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នានា រួមទាំងវិស័យព្រៃឈើ ដែលស្ថិតនៅក្រោម JCM តាមបែបបរិមាណ ដោយប្រើវិធីសាស្ត្រវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV) ហើយអាចជួយឱ្យសម្រេចបាននូវគោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នរបស់ជប៉ុន ក៏ដូចជាការអនុវត្តសកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នដែលសមស្របនៅកម្ពុជា។ មកទល់បច្ចុប្បន្ន ជប៉ុនបានចុះហត្ថលេខាលើឯកសារទ្វេភាគី ដើម្បីបង្កើត JCM ជាមួយ១០ ប្រទេស រួមមាន ម៉ុងហ្គោលី បង់ក្លាដែស អេត្យូពី កេនយ៉ា ម៉ាល់ឌីវ វៀតណាម ឡាវ ឥណ្ឌូនេស៊ី កូស្តារីកា និងកោះប៉ាឡាវ។